# I- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៥៦ អនក្រ.បក
### ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

***

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- ផ្អែកតាមអនុសញ្ញាស្តីអំពីសិទ្ធិរបស់កុមារ ដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានចុះហត្ថលេខានៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩២ និងបានផ្តល់សច្ចាប័ន នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ ១៩៩២
- យោងសេចក្តីថ្លែងការណ៍ជាន់ខ្ពស់ជាសកល ដើម្បីកុមារដែលព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ បានឡាយព្រះហស្តលេខា នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៣
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

### សំរេច

**មាត្រា ១.-** បង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ហៅកាត់ "ក.ជ.ក.ក" ដែលមានសមាសភាពដូចខាងក្រោម :

១-សម្តេច នាយករដ្ឋមន្ត្រី ជាប្រធានកិត្តិយស
២-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ជាប្រធាន
៣-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១រូប ជាអនុប្រធាន
៤-តំណាងក្រសួងមហាផ្ទៃ ១រូប ជាអនុប្រធាន
៥-តំណាងក្រសួងអប់រំ យុវជន និងកីឡា ១រូប ជាអនុប្រធាន
៦-តំណាងក្រសួងសុខាភិបាល ១រូប ជាអនុប្រធាន

៧-តំណាងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ១រូប ជាអនុប្រធាន
៨-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូប ជាសមាជិក
៩-តំណាងក្រសួងផែនការ ១រូប ជាសមាជិក
១០-តំណាងក្រសួងយុត្តិធម៌ ១រូប ជាសមាជិក
១១-តំណាងក្រសួងព័ត៌មាន ១រូប ជាសមាជិក
១២-តំណាងក្រសួងធម្មការ និងសាសនា ១រូប ជាសមាជិក
១៣-តំណាងក្រសួងអភិវឌ្ឍន៍ជនបទ ១រូប ជាសមាជិក
១៤-តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ១រូប ជាសមាជិក
១៥-តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ១រូប ជាសមាជិក
១៦-តំណាងកាកបាទក្រហមកម្ពុជា ១រូប ជាសមាជិក
១៧-តំណាងក្រសួងការពារជាតិ ១រូប ជាសមាជិក
១៨-តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ១រូប ជាសមាជិក
១៩-តំណាងក្រសួងទេសចរណ៍ ១រូប ជាសមាជិក

មាត្រា ២ ._ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ " ក.ជ.ក.ក " មានបេសកកម្មដូចតទៅ :

-ធានាកិច្ចសហការសំរបសំរួលពីគ្រប់ស្រប់ក្នុងការអនុវត្តន៍

-ត្រួតពិនិត្យ តាមដាន និងវាយតម្លៃ លើគោលនយោបាយទាំងឡាយ និងកម្មវិធីដែលពាក់ទងទៅនឹងការរស់រានមានជីវិត ការអភិវឌ្ឍន៍ ការការពារ និងលើកកំពស់សុខុមាលភាព ការចូលរួមចំណែករបស់កុមារកម្ពុជា

មាត្រា ៣ ._ ដើម្បីសំរេចនូវបេសកកម្មខាងលើនេះ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ " ក.ជ.ក.ក " មានភារកិច្ចដូចតទៅ :

-សំរាប់ការងារពីគ្រោះយោបល់ សំរបសំរួលសកម្មភាពទាំងឡាយ ដែលពាក់ព័ន្ធនឹងបញ្ហា កុមារ នៅក្នុងប្រទេសកម្ពុជា ។

-ជួយរាជរដ្ឋាភិបាលក្នុងការតាមដាន និងធ្វើរបាយការណ៍លើបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងកុមារដូចជាអនុសញ្ញាស្តីពីសិទ្ធិរបស់កុមារ និងកម្មវិធីសកម្មភាពជាតិសំរាប់កុមារ ។

-ស្រាវជ្រាវ និងជូនព័ត៌មាន ស្តីពីសេចក្តីត្រូវការ និងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងកុមារកម្ពុជាជូនទៅរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គការនានា ដែលមានសមត្ថកិច្ច ។

-ទំនាក់ទំនងជាមួយសហគមន៍ជាតិ និង អន្តរជាតិដែលមានការងារប្រហាក់ប្រហែលគ្នា ដើម្បីប្តូរយោបល់ បទពិសោធន៍ និងទស្សនៈរីកចំរើន ដែលពាក់ទងនឹងគោលដៅរួមក្នុងការកែលំអស្ថានភាពរបស់កុមារ ។

មាត្រា ៤ ._ "ក.ជ.ក.ក " មានរចនាសម្ព័ន្ធចាត់តាំង ដើម្បីដំណើរការដូចខាងក្រោម :

-មានអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ និងមានការិយាល័យមួយចំនួន សំរាប់បំពេញការងារ ដែលមានទីតាំងនៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

-អាចបង្កើតអនុគណៈកម្មការជំនាញ និងគណៈកម្មការតំបន់ ដើម្បីធ្វើការងារមួយរយៈតាមការកំណត់ ។

-មានគណៈកម្មការទីប្រឹក្សាមួយ ដែលមានសមាសភាពជាអ្នកជំនាញ ដើម្បីជួយ "ក.ជ.ក.ក " និងអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ ។

មាត្រា ៥ ._ តំណាងភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាលជាតិ តំណាងវិជ្ជាស្ថានស្រាវជ្រាវពាក់ព័ន្ធ នឹងកុមារក្នុងស្រុក អង្គការផ្តល់ជំនួយទេ្វភាគី អាចចូលជាសមាជិកសង្កេតការណ៍ ហើយអាចចូលរួមប្រជុំតាមការអញ្ជើញរបស់ "ក.ជ.ក.ក " ។

មាត្រា ៦ ._ អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ ប្រើប្រាស់បុគ្គលិកពីក្រសួងពាក់ព័ន្ធ ហើយចំនួនបុគ្គលិកកំណត់ដោយ "ក.ជ.ក.ក " ។

មាត្រា ៧ ._ តួនាទី ភារកិច្ច រចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ ការិយាល័យ អនុគណៈកម្មការ និងគណៈកម្មការទីប្រឹក្សា អាស្រ័យដោយ "ក.ជ.ក.ក " ជាអ្នកកំណត់សំរេច ។

មាត្រា ៨ ._ ថវិការបស់ "ក.ជ.ក.ក " ជាថវិកាមួយដោយឡែក ហើយជាឧបសម្ព័ន្ធថវិការបស់ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

មាត្រា ៩ ._ "ក.ជ.ក.ក " មានបទបញ្ជាផ្ទៃក្នុង និងប្រើត្រាមួយដោយឡែករបស់ខ្លួន ដែលមានទំហំស្មើ នឹងត្រារបស់ក្រសួង ។

មាត្រា ១០ ._ អនុក្រឹត្យលេខ ៩៣ អនក្រ .បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ១១ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងពាក់ព័ន្ធ ព្រមទាំងសមាជិក ដែលបានចែងក្នុងមាត្រា១ មានភារកិច្ចអនុវត្តន៍អនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ ៥៧ អនក្រ.បក**

**ស្តីពីការផ្ទេរឥណទាន**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា